ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

**សូមគោរពជូន**
**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**
**ក្នុងឱកាសចូលឆ្នាំថ្មីឆ្នាំសកល២០២១**

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល២០២១ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល មហាប្រសើរ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរដើម្បីបំពេញសកម្មភាពមនុស្សធម៌ និងដឹកនាំកាកបាទក្រហមកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរចំពោះវីរភាពដឹកនាំដ៏ឈ្លាសវៃ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ និងប្រជាជនប្រកបដោយឆន្ទៈមោះមុតខ្លាំងក្លា។ **សម្តេច** ជាអ្នកដឹកនាំស្ត្រីដ៏ឆ្នើមមួយរូប ហើយក៏បានដើរតួនាទីយ៉ាងសំខាន់ រួមចំណែកជាមួយរាជរដ្ឋាភិបាល លើកកម្ពស់សេចក្តីថ្លៃថ្នូរ កិត្តិយស តួនាទីរបស់ស្ត្រីនៅក្នុងសង្គមកាន់តែទូលំទូលាយ ពិសេសក្នុងសកម្មភាពមនុស្សធម៌ជួយរំលែកនិងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រទេសជាតិដែលជួបនូវវិបត្តិកូវីដ-១៩ និងប្រជាពលរដ្ឋដែលទទួលរងគ្រោះដូចជាគ្រោះមហន្តរាយផ្សេងៗប្រកបដោយប្រសិទ្ធភាពខ្ពស់ រហូតទទួលបានលទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់និងបានការគាំទ្រពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ឧត្តមភរិយា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ព្រមទាំង បុត្រាបុត្រី និងចៅប្រុសចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២០
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**